# ២ - សេចក្តីសំរេច

ភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៣

**សេចក្តីសំរេច លេខ : ២៦ សសរ**

**បង្កើតគណៈកម្មការរៀបចំបដិសណ្ឋារកិច្ចនៃការចេញដំណើរពីកម្ពុជា**

**របស់កងកម្លាំងរក្សាសន្តិភាព អង្គការសហប្រជាជាតិ « UNTAC »**

* * * * *

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់សម្តេចព្រះប្រមុខរដ្ឋ ចុះថ្ងៃទី ០២ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា
- ផ្អែកតាមសំណូមពរចាំបាច់នៃការងារ
- យោងលក្ខណសម្បត្តិរបស់មន្ត្រី

**សំរេច**

**ប្រការ ១** : បង្កើតគណៈកម្មការចំរុះមួយមានឈ្មោះថា " គណៈកម្មការរៀបចំបដិសណ្ឋារកិច្ច ក្នុងចេញដំណើរពីកម្ពុជារបស់កងកម្លាំងរក្សាសន្តិភាពអង្គការសហប្រជាជាតិ ( UNTAC ) ដែលរួមមានសមាសភាព ដូចខាងក្រោម :-

| | |
|---|---|
| ១ - ឯកឧត្តមសហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សហប្រធាន |
| ២ - ឯកឧត្តមអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការរៀបចំបុណ្យជាតិ-អន្តរជាតិ | អនុប្រធាន |
| ៣ - ឯកឧត្តមអនុរដ្ឋមន្ត្រីក្រសួងការពារជាតិឬតំណាង | អនុប្រធាន |
| ៤- ឯកឧត្តមប្រធានអគ្គសេនាធិការកងទ័ពជាតិឬតំណាង | សមាជិក |
| ៥ -តំណាងរដ្ឋមន្ត្រីក្រសួងការបរទេស | សមាជិក |
| ៦ -តំណាងរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ | សមាជិក |
| ៧-តំណាងរដ្ឋមន្ត្រីក្រសួងឃោសនាការ | សមាជិក |
| ៨.-តំណាងក្រសួងមហាផ្ទៃនិងសន្តិសុខជាតិ | សមាជិក |
| ៩-តំណាងអភិបាលក្រុងភ្នំពេញ | សមាជិក |

១០ -តំណាងនាយកដ្ឋានពិធីការគណៈកម្មាធិការបុណ្យជាតិ-អន្តរជាតិ ជំនួយការ

១១ -អ្នកស្រីអនុប្រធាននាយកដ្ឋានពិធីការទីស្តីការគណៈរដ្ឋមន្ត្រី លេខាធិការ

**ប្រការ ២ :** គណៈកម្មការដូចចែងក្នុងប្រការ ១ មានភារកិច្ច ៖

១ - រៀបចំគ្រប់ពិធីការ ដែលទំនាក់ទំនងដល់ការចេញដំណើររបស់កងកំលាំង អ៊ុនតាក់ អោយបានល្អប្រសើរទាំងខ្លឹមសារ និងរូបភាព ជាអាទិ៍ ៖

- សារលិខិត ថ្លែងអំណរគុណក្នុងនាម រដ្ឋាភិបាល
- វត្ថុអនុស្សាវរីយ៍ក្នុងនាមសាមីក្រសួង ឬ ស្ថាប័ន ដែលមានទំនាក់ទំនងធ្វើការងារផ្ទាល់ជាមួយអាជ្ញាធរ អ៊ុនតាក់
- ការសវនាការ ឬ ជួបសំណេះសំណាលរបស់សាមី ក្រសួង ឬ ស្ថាប័នដែលទាក់ទងជាមួយអាជ្ញាធរអ៊ុនតាក់ ដើម្បីសំដែងមនោសញ្ចេតនាជាភាតរៈ និងមិត្តភាពទៅវិញទៅមក ។ ល ។

២ - រៀបចំពលនាកំលាំងមហាជនគ្រប់ស្រទាប់ ចូលរួមបដិសណ្ឋារកិច្ច ជូនដំណើរក្បួនចាកចេញ របស់កងកំលាំង អ៊ុនតាក់ អោយបានអធិកអធម ពិសេសការជូនដំណើររបស់ប្រមុខអ៊ុនតាក់ យ៉ាស៊ូ ស៊ីអាកាស៊ី ។

៣ - រៀបចំពិធីជប់លៀងមួយជូនឯកឧត្តម យ៉ាស៊ូស៊ី អាកាស៊ី ប្រមុខ អ៊ុនតាក់ និង សហការីជាន់ខ្ពស់ មួយចំនួនរបស់គាត់ ។

**ប្រការ ៣ :** សមាជិកគណៈកម្មការនេះ ត្រូវអញ្ជើញចូលរួមប្រជុំតាមការកោះអញ្ជើញ របស់ប្រធាន ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីបណ្តាក្រសួងពាក់ព័ន្ធ និង មន្ត្រីដូចមានចែងក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.សហប្រធាន នៃរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី**

ហត្ថលេខា និង ត្រា

**អ៊ុំ ជន**

* * * *